# ការបង្រៀនសេចក្ដីពិតមកពី គោលលទ្ធិ និងសេចក្ដីសញ្ញា ១៣០

## ការរៀបចំមេរៀន ៖

ជំហានទី ១ ៖ ជ្រើសរើសប្រធានបទសិក្សាមួយក្នុងចំណោមប្រធានបទសិក្សាខាងក្រោម និងសិក្សាអំពីធនធានដែលបានផ្ដល់ឲ្យ ។ សូមយកចិត្តទុកដាក់ទៅលើគំនិត និងចំណាប់អារម្មណ៍ទាំងនានាមកពីព្រះវិញ្ញាណបរិសុទ្ធអំពីអ្វីដែលអ្នកកំពុងអាន ។ អ្នកក៏អាចរកឃើញធនធានផ្សេងទៀតដើម្បីពង្រឹងការយល់ដឹងរបស់អ្នកអំពីប្រធានបទដែលអ្នកបានជ្រើសរើសផងដែរ ។

ជំហានទី ២ ៖ បង្កើតគម្រោងមេរៀនរយៈពេល ៥ ទៅ ៧ នាទី សម្រាប់ប្រធានបទដែលអ្នកបានជ្រើសរើស ។ សូមពិចារណាប្រើសំណួរមួយចំនួនខាងក្រោមដើម្បីជួយឲ្យអ្នករៀបចំ ៖

- តើសេចក្ដីពិតទាំងនេះអាច ឬនឹងមានឥទ្ធិពលយ៉ាងណាទៅលើទំនាក់ទំនងរបស់យើងជាមួយនឹងព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ ?
- តើខ្ញុំអាចប្រើបទគម្ពីរ និងប្រសាសន៍របស់ព្យាការីដើម្បីជួយអ្នកដទៃឲ្យយល់កាន់តែច្បាស់អំពីប្រធានបទនេះយ៉ាងដូចម្ដេច ?
- តើខ្ញុំអាចធ្វើអ្វីខ្លះដើម្បីជួយអ្នកដទៃឲ្យចូលរួមក្នុងមេរៀននេះ និងធ្វើជាអ្នកចូលរួមយ៉ាងសកម្ម ?
- តើខ្ញុំអាចចែកចាយបទពិសោធន៍អ្វីខ្លះ ឬតើខ្ញុំអាចថ្លែងទីបន្ទាល់អំពីអ្វី ?
- តើខ្ញុំអាចធ្វើអ្វីខ្លះដើម្បីជួយអ្នកដទៃអនុវត្តប្រធានបទនេះនៅក្នុងជីវិតរបស់ពួកគេ ?

## ធនធាន និងប្រធានបទសិក្សា ៖

#### ជម្រើសទី ១ ៖ ចំណេះដឹង និងបញ្ញានឹងមកជាមួយយើងនៅក្នុងការរស់ឡើងវិញ

### ធនធានដើម្បីសិក្សា ៖

គោលលទ្ធិ និងសេចក្ដីសញ្ញា ១៣០:១៨–១៩ សូមមើលផងដែរ គោលលទ្ធិ និងសេចក្ដីសញ្ញា ៨៨:១១៨; ៩៣:៣៦

អែលឌើរ នែល អេ ម៉ាក់ស្វែល ( ឆ្នាំ ១៩២៦–ឆ្នាំ ២០០៤ ) ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានបង្រៀន ៖



ប្រសិនបើយើងពិចារណាគ្រាន់តែអំពីអ្វីដែលវានឹងមកជាមួយយើងក្នុងការរស់ឡើងវិញ វាហាក់ដូចជាច្បាស់ណាស់ថា បញ្ញារបស់យើងនឹងកើតឡើងជាមួយយើង ដែលមានន័យថា មិនមែនគ្រាន់តែ IQ របស់យើងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសមត្ថភាពរបស់យើងក្នុងការទទួល និងអនុវត្តសេចក្ដីពិតផងដែរ ។ ទេពកោសល្យ គុណលក្ខណៈ និងជំនាញរបស់យើងនឹងកើនឡើងជាមួយយើង ហើយប្រាកដណាស់សមត្ថភាពរៀនសូត្ររបស់យើង កម្រិតនៃការដាក់វិន័យខ្លួនឯង និងសមត្ថភាពធ្វើការរបស់យើងក៏នឹងកើនឡើងជាមួយយើងផងដែរ ។ ( នែល អេ ម៉ាក់ស្វែល *We Will Prove Them Herewith* [ ឆ្នាំ ១៩៨២ ] ទំព័រ ១២ )

#### ជម្រើសទី ២ ៖ យើងទទួលបានពរមកពីព្រះតាមរយៈការគោរពប្រតិបត្តិតាមក្រឹត្យវិន័យរបស់ទ្រង់ ។

### ធនធានដើម្បីសិក្សា ៖

គោលលទ្ធិ និងសេចក្ដីសញ្ញា ១៣០:២០–២១; សូមមើលផងដែរ យ៉ូហាន ៧:១៧; គោលលទ្ធិ និងសេចក្ដីសញ្ញា ៨២:១០

ប្រធាន រ័សុល អិម ណិលសុន បានបង្រៀន ៖



ប្រសិនបើអ្នកពិតជាចង់បានពរជ័យជាក់លាក់ នោះអ្នកគួរស្វែងយល់ថាតើក្រឹត្យវិន័យអ្វីដែលគ្រប់គ្រងពរជ័យនោះ ហើយបន្ទាប់មកខិតខំគោរពប្រតិបត្តិតាមក្រឹត្យវិន័យទាំងនោះ ។ ( រ័សុល អិម ណិលសុន « The Mission and Ministry of the Savior: A Discussion with Elder Russell M. Nelson » *Ensign* ខែ មិថុនា ឆ្នាំ ២០០៥ ទំព័រ ១៩ )